# ទាក់ទងមកយើង

មជ្ឈមណ្ឌលគាំទ្រកុមារមីដ្ដលសេក្ស ("MCAC") ត្រូវបានគេដាក់នៅក្នុងអង្គភាពការពារកុមារនៃការិយាល័យមេធាវីតំបន់មីដ្ដលសេក្ស។

នៅ MCAC សេវាកម្មវេជ្ជសាស្ត្រឯកទេសត្រូវបានផ្តល់ជូនដោយអ្នកត្រួតពិនិត្យគិលានុបដ្ឋាយិកាផ្លូវភេទកុមារដែលត្រូវបានបញ្ជាក់ដោយសួងសុខាភិបាលសាធារណៈរដ្ឋម៉ាស្សាជូសេត្ស៍។


Mildrine Tulysse
Pedi SANE, Middlesex CAC
15 Commonwealth Avenue
Woburn, MA 01801
(781) 897-8422


## ចូលលេងពួកយើងតាមអនឡាញដើម្បី សិក្សាបន្ថែម

មជ្ឈមណ្ឌលគាំទ្រកុមារមីដ្ដលសេក្ស
Middlesex Children’s Advocacy Center
www.middlesexcac.org

ការិយាល័យមេធាវីតំបន់មីដ្ដលសេក្ស
Middlesex District Attorney’s Office
www.middlesexda.com

MIDDLESEX CHILDREN'S ADVOCACY CENTER

DISTRICT ATTORNEY MARIAN T. RYAN

COMMONWEALTH OF MASSACHUSETTS DEPARTMENT OF PUBLIC HEALTH

NATIONAL CHILDREN'S ALLIANCE





# កម្មវិធីពេទ្យកុមារ SANE រដ្ឋម៉ាស្សាជូសេត្ស៍

## សេវាកម្មគិលានុបដ្ឋាយិកាផ្លូវភេទកុមាររដ្ឋម៉ាស្សាជូសេត្ស៍ នៅមជ្ឈមណ្ឌលគាំទ្រកុមារមីដ្ដលសេក្ស

# សេវាកម្មខាងវេជ្ជសាស្ត្រ



នៅពេលមានការព្រួយបារម្ភ ឬរបាយការណ៍នៃការរំលោភបំពានផ្លូវភេទ កុមារមានសិទ្ធិទទួលការវាយតម្លៃផ្នែកវេជ្ជសាស្ត្រដែលអនុវត្តដោយពេទ្យដែលមានជំនាញក្នុងផ្នែកនេះ។

**គោលបំណងនៃការពិនិត្យផ្នែកវេជ្ជសាស្ត្រគឺដើម្បី:**

1. ធានានូវសុខភាព និងសុខុមាលភាពរបស់កូនលោក-អ្នក
2. ធ្វើរោគវិនិច្ឆ័យ និងព្យាបាលស្ថានភាពសុខភាពដែលអាចទាក់ទងនឹងការបំពានធ្វើបាប
3. បញ្ជាក់ប្រាប់កូនរបស់លោក-អ្នកថា អ្វីគ្រប់យ៉ាងគឺមិនអីទេជាមួយនឹងរាងកាយរបស់ពួកគេ
4. កត់ត្រានូវលទ្ធផលផ្នែករាងកាយ និងកោសល្យវិច្ឆ័យសំខាន់ៗ
5. ក្នុងករណីមានការរំលោភបំពានផ្លូវភេទមែន នឹងមានការប្រមូលភស្តុតាង ដែលអាចមានវត្តមានលើរាងកាយ ឬសម្លៀកបំពាក់របស់កូនលោក-អ្នក (ប្រសិនបើត្រូវបានគេរាយការណ៍ក្នុងកំឡុងពេលជាក់លាក់ណាមួយ)

អ្នកត្រួតពិនិត្យគិលានុបដ្ឋាយិកាផ្លូវភេទកុមារដែលត្រូវបានបញ្ជាក់ដោយក្រសួងសុខាភិបាលសាធារណៈរដ្ឋម៉ាស្សាជូសេត្ស ("Pedi SANEs") ផ្តល់ដំបូន្មានទាក់ទងនឹងចម្ងល់បញ្ហាសុខភាព និងកង្វល់នានា។ ការពិនិត្យវេជ្ជសាស្ត្ររបស់ Pedi SANE រួមបញ្ចូលទាំង បើសិនជាគេបញ្ជាក់ ឯកសារថតរូប និងការសរសេរអំពីការពិនិត្យ ការពិសោធន៍ដែលមិនរាតត្បាត និងការធ្វើតេស្តរោគវិនិច្ឆ័យ ការប្រមូលភស្តុតាងវេជ្ជសាស្ត្រ និងការប្រឹក្សាយោបល់ផ្នែកសុខភាព។

ពេទ្យកុមារ SANE ផ្តល់ជូននូវការថែទាំផ្នែកវេជ្ជសាស្ត្រប្រកបដោយក្តីមេត្តាករុណា ភាពសម្របសម្រួល និងទូលំទូលាយដែលឆ្លើយតបទៅនឹងតម្រូវការលូតលាស់ផ្នែករាងកាយ ផ្លូវចិត្ត និងសេចក្តីត្រូវការតាមប្រពៃណីរបស់កុមារនីមួយៗ។

